ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍នៃឧទ្យានជាតិបុទុមសាគរ មានផ្ទៃដីចំនួន ៨ ៩០៦ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកគីរីសាគរ និងស្រុកបុទុមសាគរ ខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញសេចក្តីសម្រេចលេខ១១២សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួលនិងដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION DEVELOPMENT GROUP CO., LTD ខេត្តកោះកុង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់ជាតំបន់សហគមន៍នៃឧទ្យានជាតិបុទុមសាគរ លើផ្ទៃដីសរុបចំនួន ៨ ៩០៦ហិកតា (ប្រាំបីពាន់ប្រាំបួនរយប្រាំមួយហិកតា) សម្រាប់ផ្តល់ជូនប្រជាជនដែលរស់នៅក្នុងមូលដ្ឋាន ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកគីរីសាគរ

និងស្រុកបុទុមសាគរ ខេត្តកោះកុង ដែលមានទីតាំងកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមានចំណុចគោលតាមនិយាមកាដូចខាងក្រោម៖

| No | X | Y | No | X | Y |
|---|---|---|---|---|---|
| 1 | 303504 | 1210323 | 29 | 302025 | 1213989 |
| 2 | 303418 | 1210677 | 30 | 301842 | 1213969 |
| 3 | 302463 | 1210697 | 31 | 301846 | 1213875 |
| 4 | 302449 | 1211630 | 32 | 301051 | 1213871 |
| 5 | 302049 | 1211627 | 33 | 301051 | 1213773 |
| 6 | 302045 | 1211578 | 34 | 300852 | 1213761 |
| 7 | 301862 | 1211582 | 35 | 300852 | 1213659 |
| 8 | 301857 | 1211497 | 36 | 300448 | 1213651 |
| 9 | 301042 | 1211497 | 37 | 300452 | 1213349 |
| 10 | 301038 | 1211926 | 38 | 299579 | 1213345 |
| 11 | 300769 | 1211930 | 39 | 299581 | 1216323 |
| 12 | 300769 | 1212260 | 40 | 301581 | 1216323 |
| 13 | 300570 | 1212260 | 41 | 301581 | 1218324 |
| 14 | 300566 | 1213367 | 42 | 306035 | 1218324 |
| 15 | 301525 | 1213371 | 43 | 307448 | 1215648 |
| 16 | 302324 | 1213505 | 44 | 309565 | 1215383 |
| 17 | 303913 | 1213786 | 45 | 309566 | 1214774 |
| 18 | 303880 | 1214165 | 46 | 314704 | 1214809 |
| 19 | 304390 | 1214170 | 47 | 316756 | 1212749 |
| 20 | 304398 | 1214223 | 48 | 318851 | 1212730 |
| 21 | 304549 | 1214235 | 49 | 320329 | 1210858 |
| 22 | 304504 | 1214475 | 50 | 321531 | 1209666 |
| 23 | 302723 | 1214333 | 51 | 321581 | 1206324 |
| 24 | 302726 | 1214124 | 52 | 317581 | 1210323 |
| 25 | 302445 | 1214103 | 53 | 315581 | 1210323 |
| 26 | 302429 | 1214307 | 54 | 313581 | 1212323 |
| 27 | 302290 | 1214327 | 55 | 307581 | 1212323 |
| 28 | 302038 | 1214327 | 56 | 305609 | 1210347 |

**មាត្រា២ .-**

តំបន់សហគមន៍នៃឧទ្យានជាតិបុទុមសាគរ ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកគីរីសាគរ និងស្រុកបុទុមសាគរ ខេត្តកោះកុង ត្រូវបានកំណត់ជាតំបន់គ្រប់គ្រងដែលបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រជាជនមូលដ្ឋាន។ រាល់ការចេញប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល។

## សម្រេច

**មាត្រា១៖**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ២ ១៧៣,២ ហិកតា (ពីរពាន់មួយរយចិតសិបបីហិកតា និងម្ភៃអា) ដែលមានទីតាំងស្ថិតក្នុងឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង សម្រាប់គោលដៅសម្បទានក្នុងការអភិវឌ្ឍវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម ដូចមានផែនទី និងនិយាមការលេខ ១៧៣៥ ខកក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ របស់សាលាខេត្តកោះកុង ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២៖**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងរ៉ែ និងថាមពល ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣៖**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- -ដូចមាត្រា៤
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ